នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/១/០៧-០៩-២០០៩-អវតក/កសចស(អបជ ៥០) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 15-Jun-2018, 11:22
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ:

ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ: សាធារណៈ:/Public

ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើសុំរបស់សហមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី**

---

**អ្នកដាក់ឯកសារ:**

**សហព្រះរាជអាជ្ញាអន្តរជាតិ**

លោក Nicholas KOUMJIAN

**ចម្លងជូន:**

**សហព្រះរាជអាជ្ញាជាតិ**

លោកស្រី ជា លាង

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម ន័យ ថុល

ចៅក្រម ហួត វុទ្ធី

ចៅក្រម Olivier BEAUVALLET

ចៅក្រម BAIK Kang Jin

**មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ទាំងអស់ក្នុងសំណុំរឿង០០៤/១**

**សហមេធាវី អ៊ឹម ចែម:**

ប៊ិត ស៊ាងលឹម

Wayne JORDASH

## I. សេចក្ដីផ្ដើម

១. សហព្រះរាជអាជ្ញាអន្តរជាតិ(“សហព្រះរាជអាជ្ញា”) ស្នើឲ្យអង្គបុរេជំនុំជម្រះទាត់ចោលចម្លើយតប របស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីជាតិតំណាងដើមបណ្ដឹងរដ្ឋប្បវេណី សុំពន្យារ ពេលវេលាកំណត់ ដើម្បីដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា (“ចម្លើយ តប”)[1]។ ចម្លើយតបរបស់ អ៊ឹម ចែម ផ្អែកលើការយល់ច្រឡំនៃវិធានផ្ទៃក្នុង[2] និងស្នើសុំយ៉ាងមាន ប្រសិទ្ធិភាពឲ្យបដិសេធចោលសិទ្ធិស្ដាប់សវនាការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី។

## II. សេចក្ដីសន្និដ្ឋាន

### *i. អ៊ឹម ចែម បកស្រាយមិនត្រូវចំពោះវិធានផ្ទៃក្នុង*

២. អ៊ឹម ចែម បញ្ចូលបញ្ហាពីរខុសគ្នាធ្វើជារឿងតែមួយ។ សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីប្ដឹង ឧទ្ធរណ៍ប្រឆាំងនឹងការច្រានចោលរបស់សហចៅក្រមស៊ើបអង្កេត (“សចស”) លើពាក្យសុំរបស់ ដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេ អនុលោមតាម *វិធាន២៣ស្ទួន(៣) វិធាន៧៧ស្ទួន* និង វិធាន ៧៤(៤)(ខ) *គឺជារឿងដាច់ដោយឡែកពីគ្នា និងខុសគ្នា* ពីសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បី ប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ អនុលោមតាមវិធាន ៧៤(៤)(ច)។ ចំណុចនេះគឺច្បាស់ ណាស់តាមរយៈពាក្យពេចន៍នៅក្នុងវិធានផ្ទៃក្នុង។

៣. មូលហេតុតែមួយគត់ដែលបានផ្ដល់ដោយ សចស ចំពោះការច្រានចោលដើមបណ្ដឹងរដ្ឋប្បវេណីនៅ ក្នុងតួយ៉ាងនេះ ការរកឃើញរបស់ពួកគាត់គឺថា អ.វ.ត.ក គ្មានយុត្តាធិការដើម្បីជំនុំជម្រះលើ អ៊ឹម ចែម ទេ[3]។ វៀរលែងតែសេចក្ដីសម្រេចស្ដីពីយុត្តាធិការបុគ្គលនៅក្នុងដីកាដំណោះស្រាយ ត្រូវបាន កែប្រែ បើមិនដូច្នោះទេ ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានទទ្បីករណ៍ដើម្បីជំទាស់ទៅនឹងការច្រានចោល ពាក្យសុំរបស់ពួកគាត់ឡើយ។ ដើម្បីឲ្យភាគីដើមបណ្ដឹងរដ្ឋប្បវេណីមួយអាចតវ៉ាដោយជោគជ័យថា

---

[1] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម ទៅនឹងសំណើរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយមានសំអាងហេតុ ជាភាសាអង់គ្លេសមុនសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ (D308/3/1/4), ២១ សីហា ២០១៧។ *សូម*អាន សារអេឡិចត្រូនិកពីអង្គបុរេជំនុំជម្រះ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ (ណែនាំឲ្យ “ភាគីក្នុងសំណុំរឿង០០៤/១ ដាក់ការឆ្លើយតបណាមួយទៅនឹងចម្លើយតបនេះ នៅត្រឹមម៉ោងការងារនៅថ្ងៃពុធ ទី២៣ ខែសីហា ឆ្នាំ២០១៧” (ន័យដើមត្រូវបានលុបចេញ)។

[2] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី៩), ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥។

[3] D307 ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ២២ កុម្ភៈ ២០១៧, កថាខណ្ឌ ១១។

ពាក្យសុំរបស់ពួកគាត់អាចទទួលយកបាន ជាដំបូងពួកគាត់ចាំបាច់ត្រូវបដិសេធលើការច្រានចោលករណីនោះរបស់ សចស ជាមុនសិន - បើគ្មានការបដិសេធនេះទេ គេក៏គ្មានទឡ្ហីករណ៍ដើម្បីប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងភាពអាចទទួលយកបាននេះដែរ។ តាមកាលៈទេសៈជាក់ស្តែងយ៉ាងនេះ វាជាការឥតប្រយោជន៍សម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ក្នុងការប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការទាត់ចោលលើពាក្យសុំរបស់ខ្លួន វៀរលែងតែ និងរហូតទាល់តែមានការកែប្រែលើសំអាងហេតុក្នុងការទាត់ចោលនោះ - មានន័យថា ការរកឃើញរបស់ សចស ស្ដីពីយុត្តាធិការបុគ្គល។

៤. អ៊ឹម ចែម ទទួលស្គាល់ថា សចស មានកាតព្វកិច្ចដើម្បីសម្រេចទៅលើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី - យ៉ាងយឺតបំផុត - ក៏ត្រឹមពេលដែលដីកាដំណោះស្រាយត្រូវបានដាក់[4]។ ហើយ សចស បានបញ្ជាក់យ៉ាងច្បាស់ថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងករណីនេះត្រូវបានច្រានចោល *"ដោយហេតុ"* នៃការរកឃើញថា អ៊ឹម ចែម "មិនស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក"[5]។ ប៉ុន្តែ អ៊ឹម ចែម សន្និដ្ឋានទាំងភ័ន្តច្រឡំថា ដើមបណ្ដឹងរដ្ឋប្បវេណីគ្មានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ) ដែលលើកលែងការចោទប្រកាន់សំណុំរឿងនេះ ដោយសារដើមបណ្ដឹងរដ្ឋប្បវេណីមិនបានប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការច្រានចោលពាក្យសុំរបស់ពួកគាត់។ ការបកស្រាយទាំងមានកំហុសរបស់ អ៊ឹម ចែម គឺបានបង្ហាញឱ្យឃើញយ៉ាងជាក់ស្ដែងនៅក្នុងការទាមទាររបស់គាត់ថា វិធានផ្ទៃក្នុង៖

> មិនផ្តល់ឱ្យអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរកឃើញថា មិនអាចទទួលយកបានដោយសហចៅក្រមស៊ើបអង្កេត នូវឱកាសឆ្លើយតបទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ដោយសហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយទេ កុំថាឡើយដល់ទៅបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាលើកលែងការចោទប្រកាន់ ប្រសិនបើ ពួកគាត់បរាជ័យក្នុងការតវ៉ានឹងដីកាសម្រេចដែលរកឃើញថា ពួកគាត់មិនអាចទទួលយកបាន[6]។

៥. ដោយអនុវត្តសំអាងហេតុរបស់ អ៊ឹម ចែម ត្រង់ចំណុចដែលដីកាសម្រេចលើភាពអាចទទួលយកបានមកដល់នៅពេលដំណាលគ្នានឹងដីកាដំណោះស្រាយ ហើយត្រូវបានផ្អែកទាំងស្រុងលើទឡ្ហីករណ៍ដូចគ្នានឹងការលើកលែងចោទប្រកាន់សំណុំរឿងទាំងមូល - ជាធរមានបដិសេធដើម្បីបណ្ដឹងរដ្ឋវេណីទាំងអស់នេះពីសិទ្ធិនីតិវិធីរបស់ពួកគេ។ សម្រាប់មូលហេតុដូចបានគូសបញ្ជាក់ខាងលើ

---

[4] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កំណត់សំគាល់ជើងទំព័រ ១៥។

[5] **D307** ដីកាសម្រេចលើភាពអាចទទួលយកពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី, ២២ កុម្ភៈ ២០១៧, កថាខណ្ឌ ១១ (សង្កត់ន័យដើម)។

[6] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១៨។

សនិទានភាពរបស់ អ៊ឹម ចែម នឹងមានន័យថា ដើមបណ្ដឹងរដ្ឋប្បវេណី *មិន*អាចប្ដឹងឧទ្ធរណ៍ដីកាដំណោះស្រាយលើកលែងចោទប្រកាន់បានឡើយ - តាមវិធីនៃការលើកលែងចោទប្រកាន់នោះ ត្រង់ចំណុចដែលពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្លាយជាមិនអាចទទួលយកបាន។ អ៊ឹម ចែម ជាធរមានស្វែងរកឲ្យបដិសេធដំណោះស្រាយតែមួយគត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលបើកចំហរសម្រាប់ពួកគេ គឺថា ត្រូវប្ដឹងឧទ្ធរណ៍ដីកាដំណោះស្រាយ (សំអាងហេតុ) អនុលោមតាមវិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុង។

៦. ការលើកឡើងបន្ថែមទៀតរបស់ អ៊ឹម ចែម ដែលថា ដើមបណ្ដឹងរដ្ឋប្បវេណីទាំងនោះខ្វះសិទ្ធិប្ដឹង ដោយសារតែ "គ្រោះដែលពួកគេបានលើកឡើងថាបានទទួលរង គឺមិនជាប់ទាក់ទងទៅនឹងបទចោទប្រកាន់ប្រឆាំងនឹងអ្នកស្រី អ៊ឹម ចែម"[7] នោះ គឺស្វែងរកឲ្យបុរេវិនិច្ឆ័យបញ្ហាមួយក្នុងចំណោមបញ្ហាស្នូលនានានៃបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)។ ដូចដែលបានរៀបរាប់លម្អិតដោយសហព្រះរាជអាជ្ញា អំពើឧក្រិដ្ឋដែលលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម មិនចាំបាច់ត្រូវ "ចោទប្រកាន់" ដោយសចស នោះទេ ដើម្បីបង្កើតបានជាផ្នែកមួយនៃការបញ្ជូនរឿងទៅជំនុំជម្រះនៅក្នុងដីកាដំណោះស្រាយនោះ[8]។ អ៊ឹម ចែម ក៏ស្វែងរកផងដែរឲ្យជាក់ជំនួសការវិភាគអង្គហេតុរបស់គាត់ លើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ត្រង់ចំណុចដែលមិនមានការសម្រេចបែបនោះធ្វើឡើងដោយ សចស[9]។

## *ii. ដើមបណ្ដឹងរដ្ឋប្បវេណីមានសិទ្ធិចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍*

៧. វិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុងផ្ដល់ឲ្យដើមបណ្ដឹងរដ្ឋប្បវេណីនូវសិទ្ធិចូលរួមក្នុងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយលើកលែងការចោទប្រកាន់លើរឿងក្ដីមួយ។ បទប្បញ្ញត្តិតែមួយគត់ គឺថា សហព្រះរាជអាជ្ញាត្រូវតែប្ដឹងឧទ្ធរណ៍ការលើកលែងចោទប្រកាន់នោះ។ ការលើកឡើងរបស់ អ៊ឹម ចែម ថា ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវតែដាក់សេចក្ដីជូនដំណឹងស្ដីពីបណ្ដឹងឧទ្ធរណ៍ ដើម្បីចូល

[7] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ ១៦។

[8] **D308/3/1/1** បណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ), កថាខណ្ឌ ១១-២២។

[9] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, ជើងទំព័រ១៧។

រួមក្នុងកិច្ចដំណើរការនីតិវិធីបណ្តឹងឧទ្ធរណ៍នោះ គឺមិនត្រូវបានគាំទ្រដោយការបកស្រាយទាំងមូលនៃវិធានផ្ទៃក្នុង ឬ តាមតក្កវិជ្ជានោះទេ។

៨. ដោយសារតែសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផ្អែកលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងការលើកលែងចោទប្រកាន់នោះ ដើមបណ្តឹងរដ្ឋប្បវេណីនឹងមិនដឹងអំពីឱកាសរបស់ខ្លួនប្តឹងឧទ្ធរណ៍នោះឡើយ រហូតទាល់តែកាលបរិច្ឆេទកំណត់បានផុត លុះត្រាតែសហព្រះរាជអាជ្ញាដាក់ការជូនដំណឹងនៃបណ្តឹងឧទ្ធរណ៍របស់ខ្លួនឲ្យបានឆាប់ ហើយវាត្រូវបានជូនដំណឹងមុនកាលបរិច្ឆេទកំណត់។ វាមិនអាចជាចំណាប់អារម្មណ៍របស់កិច្ចប្រជុំពេញអង្គទេ ដែលថាដើមបណ្តឹងរដ្ឋប្បវេណីនឹងបាត់បង់ឱកាសតែមួយ និងចុងក្រោយរបស់ខ្លួនដើម្បីត្រូវបានស្តាប់យោបល់លើបញ្ហាណាមួយ ដែលសំខាន់ និងជាស្ថាពរដូចការលើកលែងចោទប្រកាន់រឿងក្តីដែលនៅក្នុងនោះពួកគាត់បានចូលមកដើម្បីចែករំលែកបទពិសោធន៍នៃការឈឺចាប់របស់ខ្លួន ដោយសារតែការបរាជ័យលើកាលបរិច្ឆេទកំណត់ដោយបច្ចេកទេសនោះ។ ដូច្នេះ ការលើកឡើងរបស់ អ៊ុម ចែម អំពីកង្វះខាតការយកចិត្តទុកដាក់ខ្លាំងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះ វាគឺមិនសមរម្យនោះទេ[10]។

៩. ត្រង់ចំណុចដែលការបកស្រាយតាមន័យត្រង់នៃអត្ថបទមិនដាច់ស្រេចទេនោះ ច្បាប់អន្តរជាតិកំណត់ថា វាត្រូវបកស្រាយ "ដោយយោងទៅលើកម្មវត្ថុ និងគោលបំណងរបស់វា"[11]។ ដោយយោងទៅលើតួនាទី និងទីកន្លែងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅតុលាការនេះ[12] វិធាន ៧៤(៤)(ច) នៃវិធានផ្ទៃក្នុងត្រូវតែបកស្រាយឲ្យស្របជាមួយនឹងគម្រោងចូលរួមយ៉ាងពេញលេញ ដែលត្រូវបាន

---

10 **D308/3/1/5** ចម្លើយតបរបស់ អ៊ុម ចែម, កថាខណ្ឌ ១៩។

11 *សូមមើល,* មាត្រា ៣១-៣២, អនុសញ្ញាទីក្រុងវីយែនស្តីពីច្បាប់អនុសន្ធិសញ្ញា, 115 U.N.T.S 331, ចុះហត្ថលេខាថ្ងៃទី ២៣ ខែឧសភា ឆ្នាំ១៩៦៩, ចូលជាធរមាននៅថ្ងៃទី២៧ ខែមករា ឆ្នាំ១៩៨០។

12 *សូមមើល,* វិធាន២៣(១) "គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញគឺដើម្បី៖ ក-*ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ* ប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់" (គូសបញ្ជាក់បន្ថែម)។ សូមមើលផងដែរ វិធាន១២, ១២*ស្ទួន,* ១២*ស្ទួនពីរ,* ២៣*ស្ទួន,* ២៣*ស្ទួនពីរ,* ២៣*ស្ទួនបី,* ២៣*ស្ទួនបួន,* ៥៩, ៦៧(៥), ៧៤(៣), ៨០(២), ៨៨(១), ៨៩(៤), ៩១(១), ៩៤(២), ១០០, ១០១(៦)(ផ), ១០៥(គ)។ *សូមមើលបន្ថែមទៀត* មាត្រា ៣៦ថ្មី នៃច្បាប់ អ.វ.ត.ក "អង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូលជំនុំជម្រះលើបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ របស់ជនរងគ្រោះ និង របស់សហព្រះរាជអាជ្ញា ពីសាលដីការរបស់អង្គជំនុំជម្រះវិសាមញ្ញនៃសាលាដំបូង"។

បង្កើតឡើងដោយតុលាការនេះ និង ដូចដែល អ៊ឹម ចែម បានអះអាង មិនត្រូវបកស្រាយក្នុងវិធីមួយដែលបដិសេធដើមបណ្តឹងរដ្ឋប្បវេណីពីការដែលត្រូវបានស្តាប់យោបល់នោះឡើយ[13]។

### *iii. អ៊ឹម ចែម ខកខានមិនបានចង្អុលភស្តុតាងថា សិទ្ធិទទួលបាននូវការជំនុំជម្រះដ៏ត្រឹមត្រូវជាយុត្តិកម្មក្នុងការច្រានចោលដើមបណ្តឹងរដ្ឋប្បវេណី*

១០. អ៊ឹម ចែម ខកខានមិនបានចង្អុលភស្តុតាងពីការអះអាងរបស់គាត់ថា ផលប្រយោជន៍នៃយុត្តិធម៌គឺត្រូវបានបាត់បង់សិទ្ធិដោយដើមបណ្តឹងរដ្ឋប្បវេណីដាក់ចម្លើយតបមួយ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា[14]។ ផ្ទុយទៅវិញ ផលប្រយោជន៍នៃយុត្តិធម៌អនុគ្រោះដល់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានប្រឹងប្រែងប្រើសិទ្ធិរបស់គាត់ក្នុងការចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ - ជាឱកាសដែលនៅសេសសល់តែមួយដែលពួកគាត់ត្រូវបានស្តាប់នៅក្នុងសំណុំរឿង០០៤/០១។ នោះគឺអង្គបុរេជំនុំជម្រះនឹងត្រូវបានផ្តល់ព័ត៌មានបន្ថែមទៀតដោយទស្សនៈរបស់ពួកគាត់ មិនបានបាត់បង់សិទ្ធិរបស់ អ៊ឹម ចែម នោះទេ។

១១. គួរឲ្យកត់សម្គាល់ អ៊ឹម ចែម ស្នើឡើងថាការអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីចូលរួមនៅក្នុងបណ្តឹងឧទ្ធរណ៍ នឹង "រារាំងនូវភាពឆាប់រហ័ស" នៃកិច្ចដំណើរការនីតិវិធី[15]។ ការណ៍នេះបើទុកណាជា អ៊ឹម ចែម ស្នើសុំបានដោយជោគជ័យនូវពេលវេលាបន្ថែមច្រើនជាង ៣០០% និង ៥០% នៃការបង្កើនទំព័រកំណត់ក្នុងការដាក់ចម្លើយតបរបស់ពួកគាត់ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា ក៏ដោយ[16]។ តាមពិតទៅ សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី

---

[13] *សូមមើល,* វិធាន ២១(១) "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និងបទបញ្ជារដ្ឋបាល ទាំងអស់ជាធរមាន *ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍*របស់ជនសង្ស័យ ជនត្រូវចោទជនជាប់ចោទ និង *ជនរងគ្រោះ* ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង កិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដូចមានចែងក្នុងច្បាប់ ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀង។" (គូសបញ្ជាក់បន្ថែម)។ វិធាន២១ (១)(គ) "អង្គជំនុំជម្រះវិសាមញ្ញ ត្រូវធានាថា ជនរងគ្រោះត្រូវទទួលបានការជូនព័ត៌មាន ហើយសិទ្ធិរបស់ជនរងគ្រោះ ត្រូវបានការពារក្នុងអំឡុងពេលនៃដំណើរការនីតិវិធីរឿងក្តី"។

[14] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ២០។

[15] **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ២០។

[16] **D308/3/1/3** សេចក្តីសម្រេចលើសំណើបន្ទាន់របស់ អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៧ សីហា ២០១៧, កថាខណ្ឌ៤។

បានស្នើសុំពេលវេលាតិចជាងឆ្ងាយពី អ៊ឹម ចែម បានស្នើសុំសម្រាប់ដាក់ចម្លើយតប[17] បើទុកណា ជាមានការខាតបង់ធនធានយ៉ាងច្រើន រវាងដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមមេធាវីការពារក្តី អ៊ឹម ចែម។

១២. បន្ថែមលើនេះ អ៊ឹម ចែម បានរក្សា "សិទ្ធិ" ស្វែងរកការពន្យារពេលវេលាបន្ថែម បើសិនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យដាក់ចម្លើយតបរបស់ពួកគាត់។[18] ដោយទទួលបានរួចជាស្រេចនូវការពន្យារពេលវេលាបន្ថែមដ៏សំខាន់ (និងចំនួនទំព័រកំណត់) ការណ៍នេះអាចត្រូវបានគេមើលឃើញថាជាការប៉ុនប៉ងមួយក្នុងការពន្យឺតកិច្ចដំណើរការនីតិវិធីបន្តទៀតតែប៉ុណ្ណោះ។ ទោះបីជាការខ្វះខាតធនធានដែលបានអះអាងដោយ អ៊ឹម ចែម ក៏ដោយ[19] ក៏គាត់បានដាក់ចម្លើយតបដ៏សំខាន់ ទៅនឹងសំណើសុំរបស់សហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាពីរភាសាក្នុងរយៈពេលតិចជាងបីថ្ងៃ។ អាស្រ័យហេតុដូច្នេះ វាទំនងជាថា ធនធានរបស់ អ៊ឹម ចែម អាចត្រូវបានយ៉ាប់យ៉ឺន នៅពេលដែលបញ្ហាប្រសិទ្ធភាពមួយវាទំនងត្រូវធ្វើ។

## III. សេចក្តីសន្និដ្ឋាន

១៣. ចំពោះមូលហេតុដូចខាងលើនេះ សហព្រះរាជអាជ្ញា សូមគោរពស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ៖

(i) ច្រានចោលនូវចម្លើយតបរបស់ អ៊ឹម ចែម និង អនុញ្ញាតឲ្យសហមេធាវីជាតិតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដាក់ចម្លើយតបមួយទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា, ហើយនិង

---

17 **D308/3/1/4** សំណើរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ សុំពន្យារពេល និងសុំការអនុញ្ញាតដាក់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ជាភាសាអង់គ្លេសសិន ដោយសំណៅជាភាសាខ្មែរនឹងដាក់តាមក្រោយ, ១៥ សីហា ២០១៧, កថាខណ្ឌ៤។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីជាតិ បានស្នើសុំរហូតដល់ថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០១៧ ដើម្បីដាក់ចម្លើយតបជាភាសាអង់គ្លេសទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា។ អ៊ឹម ចែម បានស្នើសុំការពន្យារពេលរហូតដល់ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៧ និងបានទទួលការពន្យារពេលមួយរហូតដល់ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១៧។

18 **D308/3/1/5** ចម្លើយតបរបស់ អ៊ឹម ចែម, កថាខណ្ឌ៣។

19 **D308/3/1/2** សំណើបន្ទាន់របស់ អ៊ឹម ចែម ដើម្បីសុំពន្យារពេល និងបង្កើនចំនួនសន្លឹករបស់ចម្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ(សំអាងហេតុ) (D308/3/1/1), ១៤ សីហា ២០១៧, កថាខណ្ឌ ១២-១៤។

(ii) ចាត់ប្រភេទការដាក់ឯកសារនេះ និងការដាក់ឯកសារពាក់ព័ន្ធផ្សេងទៀតជាសាធារណៈ ដោយសារវាមិនមានសំអាងហេតុណាធ្វើជាយុត្តិកម្មក្នុងការរក្សាការសម្ងាត់ នោះទេ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៧ | **លោក Nicholas KOUMJIAN** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |